ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤១២ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប ៧៤៥៣

០៨-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤១៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឡាប្លាណេតា អង់ស្យូ** (LAPLANETA ANSIAU) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅទីក្រុងរ៉ូសស្ទឹងគុង ប្រទេសអង់គ្លេស ៧៤៦០

០៨-៩-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៩០៧/៤១៥ ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាននៃកងយោធពលខេមរភូមិន្ទ ៧៤៦១

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១២-៩-២០០៧ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា ៧៤៦៣

១៣-៩-២០០៧ -អនុក្រឹត្យលេខ ១២៥ អនក្រ.បក ស្តីពីការធ្វើអនុបយោគដីចំនួន ៧៥០ ហិកតា ស្ថិតនៅតាមបណ្តោយព្រែករលួស និង ពយរាប ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ៧៤៦៨

១៣-៩-២០០៧ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៤៧០

១៤-៩-២០០៧ -អនុក្រឹត្យលេខ ១២៧ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ៧៤៧២

១៧-៩-២០០៧ -អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្តីពីការទទួលស្គាល់ការបង្កើតសាកលវិទ្យាល័យចេនឡា ៧៤៧៤

១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៧៧

១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៧៨

១២-៩-២០០៧ -អនុក្រឹត្យលេខ ៧២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៧៩

១២-៩-២០០៧ -អនុក្រឹត្យលេខ ៧៣០ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ និងឋានន្តរស័ក្តិមន្ត្រីរាជការ ៧៤៨១

១៣-៩-២០០៧ -អនុក្រឹត្យលេខ ៧៣១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៧៤៨៣

១៤-៩-២០០៧ -អនុក្រឹត្យលេខ ៧៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៤៨៤

១៤-៩-២០០៧ -អនុក្រឹត្យលេខ ៧៣៣ អនក្រ.តត ស្តីពីការដូនមេដាយមុនីសារាភ័ណ្ឌ ៧៤៨៥

១៤-៩-២០០៧ -អនុក្រឹត្យលេខ ៧៣៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៤៨៦

១៤-៩-២០០៧ -អនុក្រឹត្យលេខ ៧៣៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៧៤៨៧

១៤-៩-២០០៧ -អនុក្រឹត្យលេខ ៧៣៦ អនក្រ.តត ស្តីពីការតែងតាំងមុខងារនាយទាហាន ៧៤៨៨

១៧-៩-២០០៧ -អនុក្រឹត្យលេខ ៧៣៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៧៤៩០

២.សេចក្តីសំរេច

១៨-៩-២០០៧ -សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការការពារ អង្គជំនុំជម្រះវិសាមញ្ញ ៧៤៩១

III.ការងារបណ្តាក្រសួង

១.នីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១.ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ *(ត មកពីរាជកិច្ច លេខ ៤៥...ដល់...៦៨)* ៧៤៩៣

២.សារាចរណែនាំ

០៧-៩-២០០៧ -សារាចរណែនាំលេខ ០០៣ សហវ សារាចរណែនាំបន្ថែមលើសារាចរណែនាំស្តីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន (សំរាប់ថវិកាតាមកម្មវិធី) ៧៥៤៥

៣.សេចក្តីជូនដំណឹង

១២-៩-២០០៧ -សេចក្តីជូនដំណឹងលេខ ០២០ សហវ.ឧហ ស្តីពីការហាមឃាត់ការធ្វើអាជីវកម្មទូហ្គេម(Gaming Machine) ខុសច្បាប់ ៧៥៤៧

២.នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០២-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៤៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ធី ស៊ី អិន** ៧៥៤៨

០២-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៤៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខណ្ណាធី អ៊ីមផត អិចផត** ៧៥៥០

គ

០២-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ-ឈេនតឆ្នូន** ៧៥៥២

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ូដេម** ៧៥៥៤

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាតាំខ (ខេមបូឌា) អ៊ីមផត អិចផត** ៧៥៥៦

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សួន ហាង (ខេមបូឌា) ឌីវេឡុបមេន** ៧៥៥៨

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុង លីកា អភិវឌ្ឍន៍** ៧៥៦០

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីង ឡេង ពាណិជ្ជ** ៧៥៦២

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៦៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូណាយ យ៉ាំង ខូ អិលធីឌី** ៧៥៦៤

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ សេងលី គ្រេនីង** ៧៥៦៦

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធើហ្គិន អង្គរ ខប ធើរេសិន** ៧៥៦៨

០៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ុន អាត** ៧៥៧០

០៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រី-អេល (ខេមបូឌា)** ៧៥៧២

០៧-៣-២០០៧ -លិខិតបញ្ជាក់លេខ ០៩៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មាសចំរើន ខូ អិលធីឌី** ៧៥៧៤

នស/រកត/០៩០៧/៨១២

ព្រះរាជក្រឹត្យ

ស្តីពី

ការបង្កើតអាជ្ញាធរអាងទន្លេសាប

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាប

ROYAUME DU CAMBODGE

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីជលផល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ខែមិថុនាឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

ត្រូវបានបង្កើតអាជ្ញាធរមួយ សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប មានឈ្មោះថា **អាជ្ញាធរអាងទន្លេសាប** ដែលហៅជាអក្សរកាត់ថា **អ.អ.ទ.ស** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ។

មាត្រា ២ .-

វិសាលភាពនៃតំបន់អាងទន្លេសាប ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

ជំពូកទី ២

សមាសភាព

មាត្រា ៣.-

អ.អ.ទ.ស មានសមាសភាពដូចតទៅ :

- អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ		ប្រធាន
- ឥស្សរជនជាន់ខ្ពស់មួយចំនួន		អនុប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	០១រូប	សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	០១រូប	សមាជិក

- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី ០១រូប សមាជិក
- រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១រូប សមាជិក
- អនុប្រធានឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ០១រូប សមាជិក
- ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ០១រូប សមាជិក
- ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សមាជិក
- អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក
- អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក
- អគ្គនាយកអាជ្ញាធរអប្សរា សមាជិក
- អភិបាលរាជធានីភ្នំពេញ សមាជិក
- អភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលខេត្តពោធិ៍សាត់ សមាជិក
- អភិបាលខេត្តបាត់ដំបង សមាជិក
- អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
- អភិបាលខេត្តសៀមរាប សមាជិក
- អភិបាលខេត្តកំពង់ធំ សមាជិក

ROYAUME DU CAMBODGE

- អភិបាលខេត្តឧត្តរមានជ័យ សមាជិក
- អភិបាលខេត្តព្រះវិហារ សមាជិក
- អភិបាលខេត្តកំពង់ចាម សមាជិក
- អភិបាលខេត្តកណ្តាល សមាជិក

សមាសភាពជាក់ស្តែងរបស់ **អ.អ.ទ.ស** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

ជំពូកទី ៣
ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អ.អ.ទ.ស

មាត្រា ៤.-

អ.អ.ទ.ស មានតួនាទី ភារកិច្ច សម្រាប់សម្របសម្រួល ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់អាងទន្លេសាប ដូចតទៅ :

- ជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ ជូនរាជរដ្ឋាភិបាល
- សហការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និង គម្រោងផ្សេងៗ
- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្ត-គ្រោងនឹងអនុវត្ត របស់ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់អាងទន្លេសាប ដើម្បីឱ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ពន្ធ័អនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល
- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន : កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហា ដែលអាចកើតមានជាយថាហេតុ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល
- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន-ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់

- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាលពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

មាត្រា ៥.-

អ.អ.ទ.ស មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដោយមានការណែនាំ និងចង្អុលទិសពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាព ដូចតទៅ :

- ប្រធាន អ.អ.ទ.ស	ប្រធាន
- អនុប្រធាន អ.អ.ទ.ស	អនុប្រធាន
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.អ.ទ.ស	សមាជិក
- អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអ.អ.ទ.ស	សមាជិក

មាត្រា ៦.-

អ.អ.ទ.ស ដឹកនាំដោយប្រធាន០១រូប មានឋានៈទាបបំផុតស្មើទេសរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវរួម ចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងទីប្រឹក្សាមួយចំនួន ជាជំនួយការ ។

មាត្រា ៧.-

អ.អ.ទ.ស មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅ លើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាង ក្រសួង-ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់អាងទន្លេសាប ប្រកបដោយនិរន្តរភាព ។

អគ្គលេខាធិការដ្ឋាន **អ.អ.ទ.ស** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការ អមដោយអគ្គលេខាធិការរង មួយចំនួនជាជំនួយការ ។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារទៅតាមការណែនាំរបស់ប្រធាន ។

មាត្រា ៨.-

ដើម្បីបំពេញការងាររបស់ខ្លួន ជូនរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **អ.អ.ទ.ស** ត្រូវមាន តំណាងចូលរួមតាមដាន និង ផ្តល់យោបល់នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និង អង្គប្រជុំអន្តរក្រសួងផ្សេងៗ ពាក់ព័ន្ធ នឹងការងារអាងទន្លេសាបដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬ ដោយក្រសួង-ស្ថាប័ននានា ។

អ.អ.ទ.ស មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង-ស្ថាប័ន អាជ្ញាធរដែនដីពាក់ពន្ធ័នានា ឬ ឥស្សរជន ដែលមានបទពិសោធន៍ និង សមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងរយៈពេល ៣ខែ **អ.អ.ខ.ស** ត្រូវកោះប្រជុំសាមញ្ញម្តង ។ ក្នុងករណីចាំបាច់ប្រធាន**អ.អ.ខ.ស** ឬ គណៈកម្មាធិការប្រតិបត្តិនៃ **អ.អ.ខ.ស** អាចកោះប្រជុំវិសាមញ្ញ។ ករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំកិច្ចប្រជុំតាមការណែនាំរបស់ប្រធាន ។

ក្នុងរយៈពេល ១ខែ គណៈកម្មាធិការប្រតិបត្តិនៃ **អ.អ.ខ.ស** ត្រូវប្រជុំសាមញ្ញម្តង។

មាត្រា ៩.-

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបំរើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.អ.ខ.ស** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ១០.-

អ.អ.ខ.ស មានសិទ្ធិប្រើត្រាដោយឡែក និងមានទីស្នាក់ការដែលកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១១.-

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.អ.ខ.ស**ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី៤

ប្រភពធនធានថវិកា

មាត្រា ១២.-

ប្រភពធនធានថវិការបស់ **អ.អ.ខ.ស** សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី :

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌ ថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និងវិភាគទានពីដៃគូរអភិវឌ្ឍន៍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

អ.អ.ខ.ស មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង ឬ ក្រៅប្រទេស សម្រាប់បំរើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ១៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា ១៤.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.០៩០៧.៤៣៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ: ៤០៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ឡាប្លាណេតា អង់ស្យូ LAPLANETA ANSIAU ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ១៩៦៦ នៅទីក្រុងរ៉ូសស្ទីងតុង ប្រទេសអង់គ្លេស ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០៩.៤៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧

លេខ ៤១០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៧/៤១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

ក_ តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **អ៊ួន សំអាត់** អត្តលេខ ០០១២៤១

២-ឧត្តមសេនីយ៍ត្រី **គឹម សោភ័ណ្ឌ** អត្តលេខ ០០១២៣៧

៣-ឧត្តមសេនីយ៍ត្រី **ស ខាវី** អត្តលេខ ០០១៥០០

ខ_ តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក **ញៀម ចំណាន** អត្តលេខ ០០៤១០៦

២-វរសេនីយ៍ឯក **ជៀម សំអាន** អត្តលេខ ០១០៩៧១

៣-វរសេនីយ៍ឯក **ខិន ចឿន** អត្តលេខ ០០២៣១៥

៤-វរសេនីយ៍ឯក **ឡឹ ណារី** អត្តលេខ ០០១៦០៧

៥-វរសេនីយ៍ឯក **សុខ សារ៉ែន** អត្តលេខ ០០៤០៩៦

៦-វរសេនីយ៍ឯក **ញៀម មុន្នីនាថ** អត្តលេខ ០១១០១៩

៧-វរសេនីយ៍ឯក **យ៉ែន រ៉ាយ៉េត** អត្តលេខ ០០៣៣៦២

៨-វរសេនីយ៍ឯក **ម៉ុល ខុន** អត្តលេខ ០១៩៦៩៩

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

ចរល.០៧០៩.៤៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧

លេខៈ ៤០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ១០ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥

- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រម លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់គម្រោងស្តារជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកកម្ពុជា ដោយគម្រោងឥណទានកម្ចីធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅបង្កើតក្របខ័ណ្ឌគតិយុត្តិ ក្នុងការធ្វើសម្បទានរាជាយស្ម័យយានកម្ពុជា និងបង្កើតនីតិវិធី សម្រាប់ធ្វើការអនុម័ត និងការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន។

មាត្រា ២.-

ពាក្យបច្ចេកទេស ដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ :

កិច្ចព្រមព្រៀងសម្បទាន : សំដៅដល់កិច្ចព្រមព្រៀងត្រូវចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងសម្បទានិក ដែលបង្កើតសិទ្ធិ និងកាតព្វកិច្ចនៃភាគីនីមួយៗ និងអាណត្តិ ដែលបានព្រមព្រៀងសម្រាប់ការធ្វើអាជីវកម្ម ការថែទាំ ការជួសជុល និងការអភិវឌ្ឍន៍រាជាយស្ម័យយានកម្ពុជា មុន និងក្រោយការស្តារឡើងវិញ។

សម្បទានិក : សំដៅដល់ក្រុមហ៊ុនឯកជន ដែលបានចុះបញ្ជីក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលជាភាគីមួយទទួលបានកិច្ចព្រមព្រៀងសម្បទាន។

វិសោធនកម្មលើកិច្ចព្រមព្រៀងសម្បទាន : សំដៅដល់ការកែសម្រួលកិច្ចព្រមព្រៀងសម្បទាននាពេលអនាគត ដែលធ្វើឱ្យប៉ះពាល់ដល់ចំណូលរបស់រាជរដ្ឋាភិបាលពីការធ្វើសម្បទាន ឬការបង្កើន ឬការបន្ថយទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងសម្បទាន ។

មាត្រា ៣.-

សម្បទានិកមានសិទ្ធិក្នុងការធ្វើអាជីវកម្ម ការថែទាំ ការជួសជុល និងការអភិវឌ្ឍន៍រាជាយស្ម័យយានកម្ពុជាមុន និងក្រោយការស្តារឡើងវិញ ។

អាណត្តិ និងល័ក្ខខ័ណ្ឌនៃការធ្វើសម្បទានត្រូវចែងនៅក្នុងកិច្ចព្រមព្រៀងសម្បទាន ។

ជំពូកទី ២
នីតិវិធីសម្រាប់អនុម័តកិច្ចព្រមព្រៀងសម្បទាន

មាត្រា ៤.-

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវជ្រើសរើសសម្បទានិក តាមរយៈការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ហើយត្រូវចរចាលើអាណត្តិ និងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងសម្បទានជាមួយសម្បទានិក ដែលបានជ្រើសរើសរួចហើយ ។

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវរៀបចំឯកសារដេញថ្លៃ សេចក្តីព្រាងកិច្ចព្រមព្រៀងសម្បទាន និងឯកសារពាក់ព័ន្ធផ្សេងទៀត ហើយត្រូវដាក់ឯកសារទាំងនោះជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច មុនធ្វើការផ្សព្វផ្សាយឯកសារដេញថ្លៃ ។

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវដាក់ស្នើកិច្ចព្រមព្រៀងសម្បទាន ដែលបានចរចារួចហើយ ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យរួចដាក់ស្នើសុំការសម្រេចពីគណៈកម្មាធិការជាតិគម្រោងផ្លូវដែកសឹង្ហបុរី-គុនមីញ មុននឹងដាក់ជូនរាជរដ្ឋាភិបាលអនុម័តជាចុងក្រោយ ។

មាត្រា ៥.-

តាមការប្រទានសិទ្ធិពីរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទាន ។

ជំពូកទី ៣
ការគ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន

មាត្រា ៦.-

ក្នុងអាណត្តិនៃកិច្ចព្រមព្រៀងសម្បទាន គណៈកម្មាធិការគ្រប់គ្រងសម្បទានត្រូវពិនិត្យ និងតាមដានការអនុវត្តនីកាតព្វកិច្ចរបស់សម្បទានិក ដែលមានចែងក្នុងកិច្ចព្រមព្រៀងសម្បទាន។ គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវរាយការណ៍រៀងរាល់ឆមាសជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៧.-

ក្នុងករណីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងសម្បទាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

មាត្រា ៨.-

គណៈកម្មាធិការគ្រប់គ្រងសម្បទាន ត្រូវមានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការការងាររបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ គណៈកម្មាធិការនេះមានសិទ្ធិទទួលការឧបត្ថម្ភគាំទ្រថវិកាពីប្រភពផ្សេងៗទៀតបាន។

ជំពូកទី ៤
អន្តរប្បញ្ញត្តិ

មាត្រា ៩.-

ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន ក្រុមការងារគ្រប់គ្រងសម្បទាន ដែលបានបង្កើតឡើងក្រោមអនុក្រឹត្យ លេខ ១១៩ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ត្រូវប្តូរឈ្មោះទៅជាគណៈកម្មាធិការគ្រប់គ្រងសម្បទានវិញ ។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ១០.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១១.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជម្រាបជូន

សម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ស៊ុន ចាន់ថុល

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគដីចំនួន ៧៥០ ហិកតា ស្ថិតនៅតាមបណ្តោយ ព្រែករលួស និង ពយារាប ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងលិខិតលេខ ៩៩៣ សជណ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងលិខិតលេខ ០០៥៦ សណ/០៧ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ របស់សាលាក្រុងព្រះសីហនុ

សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីចំនួន ៧៥០ ហិកតា ស្ថិតនៅតាមបណ្តោយព្រែកលួស និង ពយរាប ក្នុងសង្កាត់អូរត្រេះ និង សង្កាត់កំពេញ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ។

មាត្រា ២.-

ផ្ទៃដីដែលធ្វើអនុបយោគខាងលើនេះ ត្រូវស្ថិតក្រោមការចាត់ចែងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សាលាក្រុងព្រះសីហនុ និង ក្រុមហ៊ុន អ៊ែតវូត អ៊ិនវេសមេន គ្រុប កូអិលធីឌី ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងលិខិតលេខ ៩៩៣ សជណ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ៣.-

ត្រូវបានផ្តល់ជូនក្រុមហ៊ុនអ៊ែតវូត អ៊ិនវេសមេន គ្រុប កូអិលធីឌី នូវផ្ទៃដីចំនួន ៥៨៥ ហិកតានៃទំហំដីសរុប ដើម្បីអភិវឌ្ឍកំពង់ផែអន្តរជាតិ ស្ទឹងហាវក្រុងព្រះសីហនុ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរក្រុងព្រះសីហនុត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤. ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤. ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨. ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស /៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាស ឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម /១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយ ចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣៧៧,០០០,០០០ រៀល (បីរយចិតសិបប្រាំពីរលានរៀលគត់) ពីជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) និងពីជំពូក ៦៣ (ពន្ធ និង អាករ) មកជំពូក ៦០ (ការទិញ) និងជំពូក ៦៤ (បន្ទុកបុគ្គលិក) ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែងរបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យ លេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារ-អភិវឌ្ឍន៍ជនបទ

-បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សម្រេច

មាត្រា ១ : មាត្រា ៣ ថ្មី នៃអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ ត្រូវបានកែសម្រួលដូចខាងក្រោម :

មាត្រា ៣ ថ្មី : ភារកិច្ចចំបងរបស់ធនាគារអភិវឌ្ឍន៍ជនបទរួមមាន :

១- ផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលមានសកម្មភាពទ្រទ្រង់សេដ្ឋកិច្ចជនបទ ។

២- ចរចារជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីទាក់ទាញហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានសំរាប់ពង្រីកសកម្មភាពរបស់ធនាគារ ។

៣- សហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនានា ក្នុងការផ្តល់ឥណទានដើម្បីអនុវត្តគម្រោងក្នុងវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងសេដ្ឋកិច្ចជនបទ ។

៤- ជំរុញការបណ្តុះបណ្តាលផ្នែកជំនាញដល់បុគ្គលិកប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

៥- អាចអនុវត្តគម្រោងឥណទានតាមសំណើរបស់ដៃគូអភិវឌ្ឍន៍ ក្នុងកាលៈទេសៈដែលប្រតិបត្តិករមីក្រូហិរញ្ញវត្ថុពុំអាចអនុវត្តបាន ។

មាត្រា ១៣ ថ្មី: ធនាគារអភិវឌ្ឍន៍ជនបទ អាចផ្តល់ឥណទានដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ពិសេសណាមួយរបស់រាជរដ្ឋាភិបាល ឬ គំរោងពិសេសផ្សេងៗទៀត ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តនូវអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៧

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់ការបង្កើតសាកលវិទ្យាល័យចេនឡា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៣០៣ / ១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យចេនឡា** "Chenla University" សរសេរកាត់ជាភាសាខ្មែរ "ស.ច.ឡ" សរសេរកាត់ជាភាសាអង់គ្លេស "C.L.U"។ សាកលវិទ្យាល័យចេនឡា មានទីតាំងស្ថិតនៅអាគារលេខ ៤៣ ផ្លូវលេខ ២៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ២ : សាកលវិទ្យាល័យចេនឡា ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យប្រាំ :

- មហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យ គណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម
- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មហាវិទ្យាល័យ វិស្វកម្ម

សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ (ប្រាំមួយ) ខែ។ ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យ មុខជំនាញ ប្រភេទបណ្តុះបណ្តាលដទៃទៀត ឬប្តូរទីតាំងថ្មី ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៣ : សាកលវិទ្យាល័យចេនឡា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យចេនឡា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៤ : សាកលវិទ្យាធិការ មានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យនេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម។
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងរបស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- គោរពតាមកិច្ចសន្យា ដែលសាកលវិទ្យាល័យចេនឡា បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា។
- ធ្វើរបាយការណ៍អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

- ធ្វើរបាយការណ៍អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

មាត្រា ៥ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យចេនឡា និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវបានផ្តល់ឱ្យដោយសាកលវិទ្យាល័យចេនឡា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យចេនឡា បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យចេនឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....៧៧២.អនក្រ....បស្រ

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ សាលាភត្ត កុដិ សាលាធម្មវិន័យ ចេតិយ និងប្រាង្គប្រាសាទ នៅ វត្តរឿងរង្សី ហៅ វត្តចាហួយ ឃុំឫស្សីក្រាំង ស្រុកមោងឫស្សី និងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ នៅសាលាបឋមសិក្សាអូរដំបង ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

១-អង្គការ School Aid Japan		ថវិកាចំនួន	៣៣.០០០ ដុល្លារ
២-ឧបាសក ស៊ឺ ស៊ីម	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	៣៣.០០០ ដុល្លារ
៣-ឧបាសក ហ៊ឹម តាញ់	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	២២.៣០០ ដុល្លារ
៤-លោក ទ៉ែត សយ	ប្រធានគណៈកម្មការអាចារ្យវត្តរឿងរង្សី	ថវិកាចំនួន	១០.២០០ ដុល្លារ
៥-លោក ស៊ឺ កុសល	ប្រធានគណៈកម្មការសាងសង់វត្តរឿងរង្សី	ថវិកាចំនួន	១០.៣០០ ដុល្លារ
៦-លោក តាញ់ នេន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	១០.៣៥០ ដុល្លារ
៧-ឧបាសិកា ឯក ខយ	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	១២.៥០០ ដុល្លារ
៨-ឧបាសិកា តែវ យេន	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន	១១.៣០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២៨ .អនក្រ-បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ក្នុងការជួយកសាងសាលាធម្មសភា ០១ខ្នង និង កុដិ ០១ខ្នង នៅវត្តព្រៃខ្ពស់ ឃុំព្រៃខ្ពស់ ស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	នុំ	ហុក	បច្ច័យ ចំនួន ១០.000 ដុល្លារ
២-លោក	ម៉ក	ត្រាឌុត	ថវិកា ចំនួន ១០.000 ដុល្លារ
៣-លោក	ទាំង	សុខ្ខសាវ័ន	ថវិកា ចំនួន ១០.000 ដុល្លារ
៤-លោក	ស	សារ៉េម	ថវិកា ចំនួន ១០.000 ដុល្លារ
៥-លោក	ម៉ក	សាទិត	ថវិកា ចំនួន ១០.000 ដុល្លារ
៦-លោក	អ៊ុន	តុង	ថវិកា ចំនួន ១០.000 ដុល្លារ
៧-លោក	ម៉ក	ឈារ៉ែន	ថវិកា ចំនួន ១០.000 ដុល្លារ
៨-លោក	រ៉ែត	ឈឿ	ថវិកា ចំនួន ១០.000 ដុល្លារ

ខ.មេដាយសំរិទ្ធស្ថាបនាជាតិ :

-លោក	អេង ប៊ុនអៀន	ថវិកា ចំនួន ២.៨៨០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៩ អនក្រ-បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោកអ៊ុំព្រឹទ្ធាចារ្យ **ហុង ជន** សប្បុរសជននៅខេត្តកំពង់ឆ្នាំង ជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកកំពង់លែង ថវិកាចំនួន ២៣.៣០០ ដុល្លារ

២-លោក **ផន សំបូរ** សប្បុរសជននៅខេត្តកំពង់ឆ្នាំង ជួយកសាងសមិទ្ធផលនានា នៅក្នុងស្រុកកំពង់លែង ថវិកាចំនួន ២៨.៥០០ ដុល្លារ

៣-ឧបាសិកា **សូ ហាន** សប្បុរសជនខ្មែររស់នៅប្រទេសញូស៊ីលេន ជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសិលាមណី ស្រុករលាប្អៀរ ថវិកា ចំនួន ១១.២១៥ ដុល្លារ

៤-លោក **ម៉ៅ ស៊ុន** និងអ្នកស្រី **មាស ហុន** សប្បុរសជនខ្មែររស់នៅប្រទេសញូស៊ីលេន ជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តសិលាមណី ស្រុករលាប្អៀរ ថវិកា ចំនួន ១០.៣៦៣ ដុល្លារ

៥-លោក **ហូ ជា** សប្បុរសជនខ្មែររស់នៅប្រទេសញូស៊ីលេន ជួយកសាងព្រះវិហារ និង សមិទ្ធផលនានា នៅវត្តសិលាមណី ស្រុករលាប្អៀរ ថវិកាចំនួន ១០.១២៥ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ឧត្តមសេនីយ៍ត្រី **ឡុង ទិចិត្រ** សប្បុរសជននៅទីក្រុងភ្នំពេញ ជួយកសាងព្រះវិហារ និងសមិទ្ធផលនានា នៅវត្តវាលុកចុល្លារាម ស្រុករលាប្អៀរ ថវិកាចំនួន ៥.១៥០ ដុល្លារ

២-លោក **លឹម ចាន់** សប្បុរសជននៅខេត្តកំពង់ឆ្នាំង ជួយកសាងសមិទ្ធផលនានា នៅស្រុកកំពង់លែង ថវិកាចំនួន ៥.០៩២ ដុល្លារ

៣-លោក **ហុង ទិចិត្រ** សប្បុរសជននៅខេត្តកំពង់ឆ្នាំង ជួយកសាងសមិទ្ធផលនានា នៅស្រុកកំពង់លែង ថវិកាចំនួន ៦.៩៩០ ដុល្លារ

៤-លោក **ហុង ម៉េងអាន** សប្បុរសជននៅខេត្តកំពង់ឆ្នាំង ជួយកសាងសមិទ្ធផលនានា នៅស្រុកកំពង់លែង ថវិកាចំនួន ៥.៩១០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៣០...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតម្លើងថ្នាក់ និងឋានន្តរសក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

ស ម្រេ ច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិជូនមន្ត្រីរាជការដូចមានរាយនាមខាងក្រោម :

១- ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

១	លោក **ញាណ សារោ**	ពីអនុមន្ត្រីថ្នាក់លេខ ៤	ទៅវរមន្ត្រីថ្នាក់លេខ ៦
២	លោក **ហ៊ុំទ សុខណ្ណ**	ពីអនុមន្ត្រីថ្នាក់លេខ ៦	ទៅវរមន្ត្រីថ្នាក់លេខ ៧
៣	លោក **ឡាយ បូរិន**	ពីអនុមន្ត្រីថ្នាក់លេខ ៧	ទៅវរមន្ត្រីថ្នាក់លេខ ៨
៤	លោកជំទាវ **ឃឹម ចំរើន**	ពីភ្នាក់ងាររដ្ឋបាលថ្នាក់លេខ ២	ទៅអនុមន្ត្រីថ្នាក់លេខ ៩

២-ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

៥	ឯកឧត្តម **ជា អូន**	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ថ្នាក់លេខ ៤	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ ៦

៣-ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

៦	លោក **អ៊ុំទ សុបុណ្ណ**	ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ថ្នាក់លេខ ១១	ទៅមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែថ្នាក់លេខ១០

មាត្រា ២ : ត្រូវបានតម្លើងថ្នាក់តាមគំរិតសញ្ញាប័ត្រជូនមន្ត្រីរាជការដូចមានរាយនាមខាងក្រោម :

១-លោកស្រី **ហេង្ស លីណា** ពីវរមន្ត្រីថ្នាក់លេខ ៣ ទៅវរមន្ត្រីថ្នាក់លេខ ២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

២-លោក **ម៉ៅ ជាខ** ពីវរមន្ត្រីថ្នាក់លេខ ៤ ទៅវរមន្ត្រីថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ

មាត្រា ៣ : មន្ត្រីរាជការដូចមានចែងក្នុងមាត្រា ២ ខាងលើត្រូវបានរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៧

ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៣ [illegible]

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ **ឃុន ឈាន** អត្តលេខ ០១៩៧០៨ ជំនួយការ ខុទ្ទកាល័យ សម្តេចប្រធានព្រឹទ្ធសភា

២-វរសេនីយ៍ទោ **លី សេងឃុង** អត្តលេខ ១៣៨៦៨៨ ជំនួយការ ខុទ្ទកាល័យ សម្តេចប្រធានព្រឹទ្ធសភា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រី នៃសមាគមន៍មិត្តភាពអាស៊ីខ្មែរ ចំនួន ០២រូប ដែលបានខិតខំស្វែងរកជំនួយជាថវិកា និងសម្ភារៈសំរាប់ចូលរួមកសាង អភិវឌ្ឍន៍ប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ដូចមានរាយនាមខាងក្រោម :-

១-លោក **ឃឿន គង់** នាយកប្រតិបត្តិរង សមាគមន៍មិត្តភាពអាស៊ីខ្មែរ

២-លោក **ហេង ឌី** ប្រធានកម្មវិធីអភិវឌ្ឍន៍ នៃសមាគមន៍មិត្តភាពអាស៊ីខ្មែរ ប្រចាំខេត្តតាកែវ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៣៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តតាកែវ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូន ឯកឧត្តម **ហូ វិចិត្រ** អនុប្រធាន សហគមន៍មិត្តភាពអាស៊ីខ្មែរ ដែលមានស្នាដៃល្អនិងគុណបំណាច់ខ្ពស់ ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HR+

